# ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ៖ សៀវភៅណែនាំសម្រាប់អាជីវកម្ម



EPA VICTORIA
Environment Protection Authority Victoria
VICTORIA State Government

Translated publication: 1765
ការបោះពុម្ពផ្សាយ 1695.1*  ខែសីហា ឆ្នាំ២០១៨
*នេះជំនួស 1695  បោះពុម្ពផ្សាយនៅខែឧសភា ឆ្នាំ២០១៨

អនុញ្ញាត និងបោះពុម្ពផ្សាយដោយ EPA Victoria
Level 3, 200 Victoria Street, Carlton VIC 3053
1300 372 842 (1300 EPA VIC)

ការបោះពុម្ពផ្សាយនេះ អាចរកឃើញនៅតាមអនឡាញជាសណ្ឋាន PDF នៅតាមវិបសៃ **epa.vic.gov.au**

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែភាសា ឬចង់បកប្រែឯកសារនេះ
សូមហៅទូរស័ព្ទលេខ
131 450 ហើយប្រាប់ពីភាសាដែលអ្នកនិយមពេញចិត្ត។

## មាតិកា

**សេចក្តីណែនាំ ........ 4**
*គោលបំណង ........ 4*
*អំពីសៀវភៅណែនាំនេះ ........ 4*
*ជំហានទាំងឡាយដើម្បីគ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យ ........ 6*
*វិធីសាស្ត្រសម្រាប់កំណត់ពីគ្រោះថ្នាក់ ........ 7*
*កំណត់ពីសកម្មភាពអាជីវកម្ម ........ 7*
*ការត្រួតពិនិត្យកន្លែងការងារ ........ 7*
*សិក្ខាសាលា និងកិច្ចប្រជុំ ........ 7*
*ការប្រើប្រាស់ព័ត៌មានដែលអាចរកបាន ........ 7*
**ជំហានទីពីរ៖ វាយតម្លៃហានិភ័យ ........ 8**
*វាយតម្លៃភាពទំនងជាកើតមានឡើង ........ 8*
*វាយតម្លៃផលវិបាក ........ 9*
*គណនាពីចំណាត់ថ្នាក់ហានិភ័យ ........ 9*
**ជំហានទី៣៖ អនុវត្តការគ្រប់គ្រង ........ 12**
*ការគ្រប់គ្រងដើម្បីទប់ស្កាត់ និងបន្ធូរបន្ថយ ........ 12*
*បញ្ជីគ្រោះថ្នាក់ និងហានិភ័យ ........ 13*
**ជំហានទី៤៖ ផែកមើលការគ្រប់គ្រង ........ 14**
*ការផែកមើលការគ្រប់គ្រង ........ 14*
*ការរក្សាការគ្រប់គ្រងដោយប្រសិទ្ធភាព ........ 14*
**ឯកសារភ្ជាប់: ឧទាហរណ៍អំពីបញ្ជីគ្រោះថ្នាក់ និងហានិភ័យ ........ 15**

## សេចក្តីណែនាំ

មានហានិភ័យនៅគ្រប់សកម្មភាពអាជីវកម្ម។ ការយល់ដឹង និងការគ្រប់គ្រង គឺមានសារៈសំខាន់ណាស់។ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យក្នុងវិធី ដែលបានរៀបចំ អាចជួយអាជីវកម្មរបស់អ្នកៈ

- រក្សាមនុស្ស និងបរិស្ថានឱ្យមានសុវត្ថិភាព និងសុខភាពល្អ
- បំពេញកាតព្វកិច្ចស្របច្បាប់របស់អ្នក
- បំពេញតាមអ្វីដែលសហគមន៍រំពឹងទុក។

ផលវិបាកនៃការបង្កគ្រោះថ្នាក់ដល់មនុស្ស និងបរិស្ថានអាចប៉ះពាល់ដល់អ្វីៗជាច្រើន។ ការបញ្ឈប់វាពីការកើតឡើងនៅដើមដំបូង អាចជួយសង្គ្រោះអាជីវកម្ម របស់អ្នកពីការបង់ថ្លៃចំណាយនានាដូចជាបណ្តឹងផ្លូវច្បាប់ និងការជូនដំណឹងដើម្បីលាងសម្អាត។

## តើសៀវភៅណែនាំគឺដើម្បីអ្វី

សៀវភៅណែនាំនេះផ្តល់ឱ្យអ្នកនូវក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ
ដែលអ្នកអាចប្រើដើម្បីជួយទប់ស្កាត់គ្រោះថ្នាក់ពីការកើតឡើងដល់សុខភាពរបស់មនុស្ស និងបរិស្ថាន។
អ្នកអាចអនុវត្តគំនិតនៅក្នុងសៀវភៅណែនាំនេះចំពោះអាជីវកម្មដែលមានទំហំ និងកម្រិតហានិភ័យខុសៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ អាជីវកម្មធំៗ ឬអស់អ្នកដែលអាចមានហានិភ័យខ្ពស់ដល់បរិស្ថាន និងសុខភាពសាធារណៈ អាចចាំបាច់ត្រូវការវិធីសាស្ត្រស្មុគស្មាញជាងនេះ។

វិធីសាស្ត្រដែលបានណែនាំនៅក្នុងសៀវភៅណែនាំនេះ គឺដូចគ្នាទៅនឹងកន្លែងការងារជាច្រើនដែលប្រើដើម្បីគ្រប់គ្រងហានិភ័យសុខភាព និងសុវត្ថិភាពការ
ងារ (OHS)។ សៀវភៅណែនាំនេះគ្របដណ្តប់តែហានិភ័យពីការបំពុល និងកាកសំណល់ប៉ុណ្ណោះ
ហើយមិនគួរយកប្រើប្រាស់ដើម្បីអនុលោមតាមកាតព្
កិច្ច OHS របស់អ្នកទេ។ សម្រាប់ព័ត៌មានអំពីការគ្រប់គ្រងកាតព្វកិច្ច OHS របស់អ្នក សូមទាក់ទង WorkSafe Victoria។

## អំពីសៀវភៅណែនាំនេះ

*អ្នកគួរប្រើព័ត៌មាននៅក្នុងឯកសារនេះ ជាការណែណាំទូទៅប៉ុណ្ណោះ។ វាមិនបានគិតថាជាដំបូន្មានផ្នែកច្បាប់ ឬវិជ្ជាជីវៈទេ ហើយអ្នកក៏មិនគួរប្រើវាជាសេចក្តី
ថ្លែងនៃច្បាប់នោះទេ។ វាមានគោលបំណងតែមួយគត់គឺជាសៀវភៅណែនាំទូទៅប៉ុណ្ណោះ ដូច្នេះវាអាចរួមបញ្ចូលទាំងការធ្វើឱ្យទៅជាទូទៅ។ អ្នកគួរតែស្វែង
រកដំបូន្មានខាងវិជ្ជាជីវៈសម្រាប់កាលៈទេសៈជាក់លាក់របស់អ្នក។*

*យើងបានព្យាយាមធ្វើឱ្យប្រាកដថាព័ត៌មានទាន់បច្ចុប្បន្នភាព ហើយមានភាពត្រឹមត្រូវ ប៉ុន្តែយើងមិនអាចធានាថាព័ត៌មាននេះមានភាពត្រឹមត្រូវ ទាន់បច្ចុប្បន្ន
ភាព ឬពេញលេញនោះទេ។*

### *តើហានិភ័យគឺជាអ្វី?*

មានពាក្យគន្លឹះមួយចំនួនដែលអ្នកត្រូវដឹង ដើម្បីឱ្យសៀវភៅណែនាំនេះមានអត្ថន័យចំពោះអ្នក។

***ហានិភ័យ*** *គឺជាការគំរាមកំហែងដែលបង្ក**គ្រោះថ្នាក់**កើតមានដល់**អ្នកទទួលរង**។*

- **គ្រោះថ្នាក់** គឺជាអ្វីដែលអាចបង្កឱ្យអន្តរាយ (ដូចជាផ្សែង ឬការកំពប់ចូលទៅក្នុងលូបង្ហូរទឹកភ្លៀង)។
- **អ្នកទទួលរង** គឺជាអ្វីដែលមានតម្លៃត្រូវបានធ្វើឱ្យអន្តរាយ (ដូចជាបរិស្ថាន ឬសុខភាពរបស់មនុស្ស)។
- **ផ្លូវចម្លង** គឺជាវិធីមួយដែលគ្រោះថ្នាក់អាចឈោងប៉ះពាល់ដល់អ្នកទទួលរង (ដូចជាខ្យល់ ទឹក ឬដី)។

មានកត្តាពីរដែលបង្កើត**ហានិភ័យ**៖ ***ភាពទំនងជាកើតមានឡើង*** និង ***ផលវិបាក***។

- ***ភាពទំនងជាកើតមានឡើង*** គឺជាសក្តានុពល ឬឱកាសដែលគ្រោះថ្នាក់នឹងបង្កឱ្យអន្តរាយ។
- ***ផលវិបាក*** គឺជាកម្រិតនៃភាពអន្តរាយ ឬឥទ្ធិពលដែលគ្រោះថ្នាក់អាចបណ្តាលឱ្យកើតមាន។

អ្នកអាចដាក់**ការត្រួតពិនិត្យ**នៅនឹងកន្លែងដើម្បីគ្រប់គ្រងហានិភ័យ។ ការត្រួតពិនិត្យអាចរួមបញ្ចូល៖

- ***ការលុបបំបាត់*** ឬការកម្ចាត់ចោលគ្រោះថ្នាក់
- ***ការដាក់ជំនួស*** គ្រោះថ្នាក់សម្រាប់អ្វីផ្សេងទៀតដែលមានហានិភ័យទាប
- ***ការគ្រប់គ្រងបែបវិស្វកម្ម*** ដែលបញ្ឈប់ការបំពុលពីការកើតមានឡើង ឬបញ្ឈប់វាពីការរាលដាល - ដូចជាម៉ាស៊ីនបិទដោយស្វ័យប្រវត្តិ
ឬជញ្ជាំងទប់ការពារ (ជញ្ជាំងទប់ការពារ គឺជាជញ្ជាំងការពារនៅជុំវិញកន្លែងផ្ទុក ដើម្បីទប់ស្កាត់ការលេចធ្លាយណាមួយ)
- ***ការគ្រប់គ្រងរដ្ឋបាល*** ដូចជាដំណើរការការងារ ឬប្រព័ន្ធត្រួតពិនិត្យ។

## ជំហានទាំងឡាយដើម្បីគ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យ

វិធីសាស្ត្រវាយតម្លៃ និងត្រួតពិនិត្យហានិភ័យមានបួនជំហាន (មើលតារាងទី១)។ វិធីសាស្ត្រនេះ គឺជាដំណើរការបន្តដែលត្រឡប់ទៅជំហានទី១ បន្ទាប់ពីអ្នក បានដាក់ការត្រួតពិនិត្យនៅនឹងកន្លែង។

***រូបភាពទី១៖ ជំហានទាំងឡាយដើម្បីត្រួតពិនិត្យគ្រោះថ្នាក់ និងហានិភ័យ***




| *ជំហាន* | *សកម្មភាព* | *ការពិពណ៌នា* |
|---|---|---|
| 1 | **កំណត់ពីគ្រោះថ្នាក់** | តើមានគ្រោះថ្នាក់អ្វីខ្លះដែលអាចបណ្តាលឱ្យអន្តរាយ? |
| 2 | **វាយតម្លៃហានិភ័យ** | តើមានកម្រិតហានិភ័យអ្វីខ្លះ ផ្អែកលើភាពទំនងជាកើតមានឡើង និងផលវិបាក? |
| 3 | **អនុវត្តការគ្រប់គ្រង** | តើអាជីវកម្មអាចធ្វើអ្វីខ្លះដើម្បីកម្ចាត់ចោល ឬកាត់បន្ថយហានិភ័យ? |
| 4 | **ឆែកមើលការគ្រប់គ្រង** | ពិនិត្យមើលការគ្រប់គ្រងដែលអាជីវកម្មប្រើប្រាស់ ដើម្បីប្រាកដថាវាកំពុងដំណើរការ។ |

***តារាងទី១៖ ជំហានទាំងឡាយដើម្បីគ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យ***

# ជំហានទី 1: កំណត់ពីគ្រោះថ្នាក់




## អ្វីដែលត្រូវស្វែងរកមើល

គ្រោះថ្នាក់សម្រាប់សកម្មភាពពាណិជ្ជកម្ម និងឧស្សាហកម្មរួមបញ្ចូលនូវអ្វីៗដែលអាចបង្កឱ្យអន្តរាយដល់មនុស្ស ឬបរិស្ថាន។ តារាងខាងក្រោមចុះរៀបរាប់អំពីគ្រោះថ្នាក់ទូទៅមួយចំនួន។

***តារាង២៖ គ្រោះថ្នាក់ទូទៅនៅតាមកន្លែងការងារដែលប៉ះពាល់ដល់បរិស្ថាន និងសុខភាពមនុស្ស***

| គ្រោះថ្នាក់ | ការពិពណ៌នា | ប្រភព ឬបុព្វហេតុទូទៅ: |
|---|---|---|
| **ការកំពប់សារធាតុគីមី** | សារធាតុគីមីអាចបណ្តាលឱ្យខូចកខ្វក់ដី ទឹកសាប និងផ្លូវ ទឹកដែលនៅក្បែរៗ ហើយប៉ះពាល់ដល់សុខភាពរបស់ មនុស្ស។ | - ធុងដែលលេចធ្លាយ<br>- មិនមានជញ្ជាំងគ្រប់គ្រាន់ដើម្បីទប់ទាំងការពារការកំពប់<br>- ការស្តុកទុក និងការចាប់កាន់មិនបានល្អ |
| **ការខូចកខ្វក់លូបង្ហូរទឹកភ្លៀង** | លូរបង្ហូរទឹកភ្លៀងមិនបង្ហូរទៅកន្លែងសម្អាតព្យាបាល ទេ ប៉ុន្តែ វាបង្ហូរដោយផ្ទាល់ទៅកាន់ព្រែកតូចៗ ទន្លេ តំបន់ដីសើម និងឆ្នេរសមុទ្រ។ អ្វីដែលហូរចូលទៅក្នុងលូរបង្ហូរទឹកភ្លៀង នឹងចូលទៅក្នុងបរិស្ថាន ហើយអាចមានផលប៉ះពាល់ដ៏ធំ។ | - ភាពកខ្វក់ និងសំណឹក<br>- សាប៊ូ និងសារធាតុគីមីដែលបានប្រើសម្រាប់សំអាត<br>- សំរាម<br>- ប្រេង និងខ្លាញ់<br>- កន្ទុយបារី<br>- ការប្រើប្រាស់សារធាតុគីមីនៅទីខាងក្រៅ |
| **អគ្គិភ័យ ឬការផ្ទុះ** | ក៏ដូចជាការគំរាមកំហែងដល់ជីវិត និងទ្រព្យសម្បត្តិដែរ អគ្គីភ័យ និងការផ្ទុះអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ដូចជា ការហូរចេញនូវសារធាតុពុល ផ្សែងពុល និងការរាលដាល នៃធូលី។ | - ការជក់បារី<br>- ផ្កាភ្លើង<br>- ផ្ទៃក្តៅ<br>- ការស្តុកទុកមិនល្អ<br>- គ្រោះថ្នាក់អគ្គីសនី<br>- ធូលី<br>- ការបង្កអគ្គីភ័យ |
| **ធូលី** | ធូលីអាចបណ្តាលឱ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ ជាពិសេស ដល់ការដកដង្ហើមរបស់មនុស្ស បេះដូង ឈាម ចលនា ឈាមរត់។ វាក៏អាចធ្វើឱ្យលោកភ្នែក បំពង់ក និងស្បែកដែរ។ | - គ្រឿងធ្វើពីឈើ<br>- ទេសភាព<br>- ការងារស៊ីម៉ង់ត៍<br>- គំនរធូលីដែលនៅបើកចំហ<br>- ការកិន<br>- ការផ្សារ<br>- ការកាត់ ឬកាត់កំទេចសម្ភារៈ<br>- ផ្លូវថ្នល់គតក្រាលកៅស៊ូ |
| **ក្លិនស្អុយ ឬក្លិនមិនល្អ** | ក្លិនពុលកខ្វក់ អាចប៉ះពាល់ដល់សុខភាពរបស់មនុស្ស បណ្តាលឱ្យចង់ក្អួត និងឈឺក្បាល។ ក្លិនមួយចំនួនអាចបង្ហាញឱ្យឃើញឧស្ម័នពុលផងដែរ ដែលបណ្តាលឱ្យកើតមានបញ្ហាសុខភាពធ្ងន់ធ្ងរ។ | - កាកសំណល់<br>- ការប្រើប្រាស់សារធាតុគីមី<br>- លូបង្ហូរទឹក<br>- សត្វ<br>- ជីកំប៉ុស<br>- បំពង់ផ្សែង និងកង្ហារបញ្ចេញបញ្ចូលខ្យល់<br>- ឧបករណ៍កែច្នៃអាហារ |
| **ការបំពុលខ្យល់** | សារធាតុពុល ឬមានគ្រោះថ្នាក់ដែលរសាត់ចូលក្នុងខ្យល់ អាកាសពីដំណើរការ ឬផលិតកម្ម បង្កនូវការខូចកខ្វក់យ៉ាង ធ្ងន់ធ្ងរ។ | - ឡដុត<br>- ចង្ក្រាន<br>- រន្ធសម្រាប់ឱ្យខ្យល់ចេញចូលក្នុងដំណើរ ការកែច្នៃ<br>- ធុងស្តុកទុកទាំងដុលធំ<br>- ការលេចធ្លាយឧបករណ៍<br>- សារធាតុរំលាយដែលនៅបើកចំហ |
| **ទឹកសំណល់** | កាកសំណល់ពាណិជ្ជកម្ម និងទឹកកខ្វក់ដទៃទៀតពីអាជីវកម្ម អាចនាំមកនូវការខូចកខ្វក់ដែលនាំឱ្យអន្តរាយ។ | - ដំណើរការកែច្នៃ<br>- ផលិតកម្ម<br>- ឧស្សាហកម្ម |
| **សម្លេងអ៊ូរអែ** | សម្លេងអ៊ូរអែអាចរំខានដល់សហគមន៍ និងបណ្តាលឱ្យមាន ជំងឺលើសឈាម ជំងឺបេះដូង ការរំខាន ភាពតានតឹង និងការរំខានដល់ការគេង។ | - ម៉ាស៊ីន<br>- សត្វ<br>- រំញ័រ<br>- រថយន្ត និងឧបករណ៍បញ្ចេញសូរសម្លេងប៊ីប |
| **កាកសំណល់ដែលមានគ្រោះថ្នាក់** | កាកសំណល់គ្រប់គ្រងមិនបានល្អ អាចបណ្តាលឱ្យអន្តរាយ ដល់ប្រជាជន និងបរិស្ថាន។ | - កាកសំណល់ឧស្សាហកម្មប្រកបដោយគ្រោះថ្នាក់ ដែលមិនបានគ្រប់គ្រង ដឹកជញ្ជូន ឬកម្ចាស់ចោលត្រឹមត្រូវ<br>- ធូលី និងដីដែលមានសារធាតុអាបេស្តូស |
| **សារធាតុបង្កជំងឺមហារីក** | សារធាតុបង្កជំងឺមហារីក រួមមានបាក់តេរី វីរុស ឬអតិសុខុម ប្រាណដទៃទៀតដែលអាចបង្កឱ្យកើតមានជម្ងឺ។ | - មិនមានស្ថានីយលាងសម្អាតដៃគ្រប់គ្រាន់<br>- មិនចាប់កាន់កាកសំណល់តាមរបៀបអនាម័យ<br>- អាងស្តុកទឹកសំអុយហូរហៀរ<br>- ទឹកសំណល់<br>- ម្ហូបអាហារកខ្វក់<br>- កាកសំណល់សរីរាង្គ<br>- កាកសំណល់សត្វ និងសត្វព្រលាត់ស្បែក ពុំទាន់បានកាត់ជាដុំតូចៗ |




## វិធីសាស្ត្រដើម្បីកំណត់ពីគ្រោះថ្នាក់

មានវិធីជាច្រើនដើម្បីកំណត់ពីគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស និងបរិស្ថានពីការបំពុលបរិស្ថាន ឬកាកសំណល់។ នៅពេលអ្នកបានកំណត់ពីគ្រោះថ្នាក់របស់អ្នកទាំងអស់ហើយ អ្នកគួរតែកត់ត្រាទុក ហើយរៀបចំជាឯកសារអំពីវា។ អ្នកអាចប្រើ *បញ្ជីគ្រោះថ្នាក់ និងហានិភ័យ* នៅចុងសៀវភៅណែនាំនេះ។

## *ពិនិត្យមើលសកម្មភាពអាជីវកម្មរបស់អ្នក*

វាជារឿងសំខាន់ក្នុងការពិនិត្យមើលសកម្មភាពទាំងឡាយដែលអាជីវកម្មរបស់អ្នកដំណើរការ
និងរបៀបដែលវាអាចបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស
និងបរិស្ថាន។ ឧទាហរណ៍ ការរក្សាទុក និងការចាប់កាន់សម្ភារផ្សេងគ្នា ការប្រើប្រាស់សាប៊ូ ការបង្កើតទេសភាព និងការកិន គឺជាសកម្មភាពទូទៅដែលអាច
បង្កឱ្យមានគ្រោះថ្នាក់។

## *ការត្រួតពិនិត្យកន្លែងការងាររបស់អ្នក*

ការដើរជុំវិញកន្លែងការងាររបស់អ្នក គឺជាមធ្យោបាយផ្ទាល់ដើម្បីកំណត់ពីគ្រោះថ្នាក់ជាច្រើន។

ទោះជាយ៉ាងណាក៏ដោយ អ្នកមិនត្រឹមតែត្រួតពិនិត្យវត្ថុដែលមើលឃើញ ដូចជារុក្ខជាតិ ឧបករណ៍ ឬអគារ និងរចនាសម្ព័ន្ធទប់ុណ្ណោះទេ អ្នកក៏គួរតែពិនិត្យ
មើលប្រព័ន្ធការងារ និងនីតិវិធីការងាររបស់អ្នកផងដែរ។ វាអាចមានប្រយោជន៍ដោយឱ្យមាននរណាម្នាក់ដែលមិនស្គាល់ការងាររបស់អ្នក ឱ្យនៅជាមួយអ្នក នៅពេលអ្នកធ្វើការត្រួតពិនិត្យរបស់អ្នក។ មនុស្សដែលធ្វើសកម្មភាពប្រចាំថ្ងៃ អាចងាយមើលរំលងគ្រោះថ្នាក់ទូទៅ។

ចូរគិតអំពី**ផ្លូវចម្លង** និង**អ្នកទទួលរង** (មើលនិយមន័យក្នុង ‘តើហានិភ័យគឺជាអ្វី’ នៅទំព័រ 1)។
ចូរគិតថាតើមានអ្នកទទួលរងនៅក្បែរនោះឬក៏អត់ ដែលអាចនាំ
ឱ្យអន្តរាយ ដូចជាផ្ទះ ផ្លូវទឹក ឬឧទ្យាន។ ចូរគិតផងដែរអំពីផ្លូវចម្លង ដែលការបំពុលអាចប្រើដើម្បីទៅកាន់ទីកន្លែងទាំងនោះ ដូចជាស្ទឹងព្រែក ខ្យល់ និងកន្លែង លូរបង្ហូរទឹក។

## *សិក្ខាសាលា និងកិច្ចប្រជុំ*

ការរៀបចំកិច្ចប្រជុំជាមួយនិយោជិត និងភាគីពាក់ព័ន្ធគឺជាមធ្យោបាយល្អក្នុងការកំណត់ពីគ្រោះថ្នាក់។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ មនុស្សអាចនិយាយអំពី អ្វីៗដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ដូចជាដំណើរការការងារ និងសម្ភារៈដែលផ្ទុកនៅកន្លែងការងារ។

កិច្ចប្រជុំនេះអាចបង្កើតនូវគំនិតហានិភ័យដែលជាផ្នែកនៃទម្លាប់កន្លែងការងាររបស់អ្នក។
វាក៏អាចផ្តល់ឱ្យអ្នកនូវឱកាសដើម្បីរាប់បញ្ចូលមនុស្សនៅខាងក្រៅ កន្លែងការងាររបស់អ្នកដែរ ដូចជាអាជ្ញាធរអគ្គិភ័យ
ឬសាលាសង្កាត់ក្នុងតំបន់។

## *ការប្រើប្រាស់ព័ត៌មានដែលអាចរកបាន*

ព័ត៌មានដែលអាចជួយកំណត់ពីគ្រោះថ្នាក់អាចមកពីកន្លែងជាច្រើន រួមមាន៖

- សមាគមឧស្សាហកម្មដែលអាចផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីគ្រោះថ្នាក់ និងហានិភ័យថ្មីៗសម្រាប់ឧស្សាហកម្មរបស់អ្នក
- ឧស្សាហករ និងអ្នកផ្គត់ផ្គង់អាចផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីគ្រោះថ្នាក់ដែលទាក់ទងនឹងរុក្ខជាតិ សារធាតុ ឬដំណើរការ
- សន្លឹកទិន្នន័យសុវត្ថិភាព (SDS) ដែលគេធ្លាប់ហៅថាសន្លឹកទិន្នន័យសុវត្ថិភាពសម្ភារ: (MSDS) ជាញឹកញាប់មានព័ត៌មានដ៏មានប្រយោជន៍អំពី គ្រោះថ្នាក់អេកូឡូស៊ីដែលទាក់ទងនឹងផលិតផល និងវិធីដែលអ្នកអាចគ្រប់គ្រងហានិភ័យ
- ស្ថាប័នជានារ៉ាប់រង ជារឿយៗអាចផ្តល់ឱ្យអ្នកនូវព័ត៌មានដ៏មានប្រយោជន៍អំពីគ្រោះថ្នាក់ និងវិធីដែលអ្នកអាចគ្រប់គ្រងហានិភ័យ
- អ្នកឯកទេសខាងបច្ចេកទេស ភ្លើង និងសុខភាព សុវត្ថិភាព ហើយនិងបរិស្ថាន
- ការរៀបចំកាកសំណល់ពាណិជ្ជកម្មសម្រាប់ទីតាំង។

## ជំហានទី 2: វាយតម្លៃហានិភ័យ




ឥឡូវនេះ អ្នកចាំបាច់ត្រូវវាយតម្លៃគ្រោះថ្នាក់ដែលអ្នកបានកំណត់នៅក្នុងជំហានទី១ ដើម្បីគណនាពី៖

- តើវាបណ្ដាលឱ្យអន្ដរាយយ៉ាងដូចម្ដេចដែរ
- តើភាពអន្ដរាយនោះវាធ្ងន់ធ្ងរយ៉ាងណាដែរ
- តើវាទំនងជាកើតមានឡើងយ៉ាងណាដែរ។

ការវាយតម្លៃហានិភ័យ គឺជាវិធីមួយដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងអំពីគ្រោះថ្នាក់ និងហានិភ័យរបស់វា ដើម្បីឱ្យអ្នកអាចសម្រេចចិត្តថាតើត្រូវ គ្រប់គ្រងវាយ៉ាងដូចម្ដេច។

*ដើម្បីធ្វើដូច្នេះ សូមអនុវត្តតាមជំហានទាំងនេះ៖*

១. វាយតម្លៃថាតើគ្រោះថ្នាក់នេះនឹងទំនងជាបណ្ដាលឱ្យមានផលប៉ះពាល់យ៉ាងណាដែរ។

២. វាយតម្លៃពីផលវិបាក ឬភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នីមួយៗ។

៣. គណនាពីចំណាត់ថ្នាក់ហានិភ័យសម្រាប់គ្រោះថ្នាក់នីមួយៗ។

### ១. វាយតម្លៃភាពទំនងជាកើតមានឡើង

ជំហានទីមួយ គឺត្រូវវាយតម្លៃថាតើគ្រោះថ្នាក់ទំនងជាបណ្ដាលឱ្យអន្ដរាយយ៉ាងណាដែរ។ ភាពទំនងជាកើតមានឡើង គឺផ្អែកលើអ្វីដែលអ្នកដឹង ឬគួរតែដឹងអំពីគ្រោះថ្នាក់ និងរបៀបដែលកាលៈទេសៈ និងសកម្មភាពអាចប៉ះពាល់ដល់គ្រោះថ្នាក់នោះ។

**ភាពទំនងជាកើតមានឡើង អាចចំណាត់ថ្នាក់ជា៖**

- **ប្រាកដច្បាស់៖** រំពឹងថានឹងកើតឡើងជាទៀងទាត់ក្នុងកាលៈទេសៈធម្មតា។
- *ទំនងខ្លាំងណាស់៖* រំពឹងថានឹងកើតឡើងនៅពេលមួយ។
- *ទំនងជា៖* អាចកើតឡើងនៅពេលមួយ។
- *មិនទំនងជា៖* មិនទំនងជាកើតឡើងនៅក្នុងកាលៈទេសៈធម្មតាទេ។
- ***កម្រ៖*** អាចកើតឡើង ប៉ុន្តែប្រហែលជានឹងមិនដែលកើតឡើងទេ។

តារាងទី៣ ចុះបញ្ជីអំពីវិធីសំខាន់ៗដើម្បីជួយអ្នកគណនាពីភាពទំនងជាកើតមានឡើង។

| វិធីសំខាន់ៗ | ការពន្យល់ |
|---|---|
| អ្វីដែលបានកើតឡើងពីមុន | ស្វែងរកមើលអ្វីដែលបានកើតឡើងពីមុន ដូចជាព្រឹត្តិការណ៍ គ្រោះថ្នាក់ និងគ្រោះថ្នាក់ដែលហៀបនឹងកើតមាន នឹងផ្ដល់ឱ្យអ្នក នូវគំនិតល្អៗអំពីភាពទំនងជាកើតមានឡើង។ វាមានសារៈសំខាន់មិនត្រឹមគ្រាន់តែស្វែងរកមើលអាជីវកម្មផ្ទាល់ខ្លួនរបស់អ្នក ប៉ុណ្ណោះទេ តែត្រូវស្វែងរកមើលអ្វីដែលបានកើតឡើងនៅទូទាំងឧស្សាហកម្មដែរ។ |
| **ការគ្រប់គ្រងមានដាក់នៅនឹងកន្លែងរួចស្រេច** | ស្វែងរកមើលការគ្រប់គ្រងដែលអ្នកមានដាក់នៅនឹងកន្លែងរួចស្រេច ហើយថាវាមានដំណើរការល្អយ៉ាងណាដែរ។ |
| **ញឹកញាប់ដូចម្ដេចដែរ** | គ្រោះថ្នាក់អាចមាននៅទីនោះគ្រប់ពេល ឬតែមួយដងគត់។ គ្រោះថ្នាក់មាននៅទីនោះកាន់តែញឹកញាប់ នោះភាពទំនងជាកើត មានឡើងរឹតកាន់តែច្រើន ដែលនឹងបណ្ដាលឱ្យអន្ដរាយ។ |
| **ការផ្លាស់ប្ដូរស្ថានភាព** | ស្ថានភាពផ្លាស់ប្ដូរទៅតាមពេលវេលា ហើយប្រែប្រួលពេញទូទាំងឆ្នាំ។ ការផ្លាស់ប្ដូរទាំងនេះអាចប៉ះពាល់ដល់ភាពទំនងជាកើត មានឡើងនៃគ្រោះថ្នា |
| **ឥរិយាបថ** | របៀបដែលមនុស្សធ្វើ ឬបញ្ចេញអាកប្បកិរិយា អាចប៉ះពាល់ដល់ភាពទំនងជាកើតមានឡើងនៃគ្រោះថ្នាក់ដែលបណ្ដាលឱ្យ អ ប្រើឧបករណ៍តាមរបៀបមិនត្រឹមត្រូវ ឬបំពេញមុខការដោយមិនបានគិត។ |

ការគ្រប់គ្រងហានិភ័យ
ជំហានទីពីរ៖ វាយតម្លៃហានិភ័យ

### ២. វាយតម្លៃផលវិបាក




ជំហានទីពីរ គឺធ្វើការវាយតម្លៃពីភាពអន្ដរាយដែលគ្រោះថ្នាក់នីមួយៗអាចបង្ក និងពីភាពធ្ងន់ធ្ងរនៃភាពអន្ដរាយនេះអាចកើ ទេ។ វាសំខាន់ក្នុងការគិតអំពី៖

- **ការគ្រប់គ្រងមុនហានិភ័យ (ហានិភ័យដែលមានជាប់ជាមួយ) -** តើនឹងកើតមានភាពអន្ដរាយច្រើនយ៉ាងណាដែរ ប្រសិនបើមិនមានការគ្រប់គ្រងដាក់នៅនឹងកន្លែង។
- **ការគ្រប់គ្រងក្រោយហានិភ័យ (ហានិភ័យដែលនៅសល់) -** តើនឹងកើតមានភាពអន្ដរាយច្រើនយ៉ាងណាដែរ ប្រសិនបើមាន គ្រង ដាក់នៅនឹងកន្លែង។ ការនេះជួយគណនាថាតើការគ្រប់គ្រងដែលមានស្រាប់មានដំណើរការល្អដូចម្ដេចដែរ ហើយថាអ្នកត្រូវការការគ្រប់គ្រងថ្មី ឬកែលម្អវាឱ្យប្រសើរឡើង។
- បែបយ៉ាងណាដែលសកម្មភាពមានគ្រោះថ្នាក់*ត្រូវបានធ្វើ*ជាជាងថាតើវា*គួរតែ*បានធ្វើដោយបែបណា។ ឧទាហរណ៍ នេះជារបៀបដែលអ្នកធ្វើ គឺខុសគ្នាពីអ្វីដែលបានសរសេរចុះនៅក្នុងនីតិវិធី។

- ស្ថានភាពដែលស្ថិតនៅក្រៅទម្លាប់ធម្មតាទាក់ទងនឹងគ្រោះថ្នាក់ ក៏ដូចជាវិធីដែលកិច្ចការជាធម្មតាត្រូវបានសន្មត់ថាកើតឡើង។ ឧទាហរណ៍ តើស្ថាន ភាពអាកាសធាតុខ្លាំងនឹងប៉ះពាល់ដល់គ្រោះថ្នាក់បែបណាដែរ ហើយតើការគ្រប់គ្រងដែលបានដាក់នៅនឹងកន្លែងមានប្រសិទ្ធិភាពយ៉ាងណាដែរ។

អ្នកក៏គួរគិតផងដែរ អំពីផលប៉ះពាល់ដែលអាចកើតមានៈ

- ***មនុស្ស*** - និយោជិត អ្នកមកលេង អតិថិជន អ្នកម៉ៅការ បុគ្គលិកសេវាកម្មសង្គ្រោះបន្ទាន់ និងអ្នកឯទៀតដែលអាចរងផលប៉ះពាល់
- ***សហគមន៍*** - មនុស្សនៅក្នុងតំបន់ (រាប់បញ្ចូលទាំងមនុស្សដែលរស់នៅទីនោះ) អាជីវកម្ម និងសហគមន៍ទូលំទូលាយ
- ***ទ្រព្យសម្បត្តិ*** - ទ្រព្យសម្បត្តិនៅតាមទីតាំង និងទ្រព្យសម្បត្តិនៅទីជិតខាង ក៏ដូចជាតំបន់សាធារណៈ និងសហគមន៍ដែរ ដែលអាចរួមបញ្ចូល សាលារៀន មន្ទីរពេទ្យ និងផ្លូវថ្នល់ធំៗ
- ***បរិស្ថាន*** - ព្រៃក និងផ្លូវទឹកក្នុងតំបន់ ខ្យល់ និងដី។

ការពិពណ៌នាអំពីផលវិបាកចាប់ពីកម្រិតទាប ទៅខ្ពស់អាចជួយអ្នកគណនាពីហានិភ័យរបស់អ្នក។ សម្រាប់ឧទាហរណ៍នៃការពិពណ៌នាអំពីផលវិបាក សូមមើលរូបភាពទី២ៈ គំរូម៉ាទ្រីសនិភ័យ។

***តារាងទី៤ៈ សំណួរដែលត្រូវសួរដើម្បីគណនាពីផលវិបាក***

| សំណួរ | ការពន្យល់ |
|---|---|
| តើអាចកើតមានប្រភេទអន្តរាយណាអ្វីខ្លះ? | មានប្រភេទអន្តរាយជាច្រើន ហើយព្រឹត្តិការណ៍តែមួយអាចបណ្តាលឱ្យមានផលប៉ះពាល់ជាច្រើន។ ឧទាហរណ៍ ព្រឹត្តិការណ៍ដូចគ្នា អាចបណ្តាលឱ្យអន្តរាយដល់បរិស្ថាន ក៏ដូចជាសុខភាពរបស់មនុស្សដែរ។ |
| តើអ្វីខ្លះដែលអាចប៉ះពាល់ដល់ភាពធ្ងន់ធ្ងរនៃគ្រោះ ថ្នាក់? | ផលវិបាកនៃហានិភ័យអាចប្រែប្រួលក្នុងកាលៈទេសៈខុសគ្នា។ ឧទាហរណ៍ អគ្គិភ័យអាចកាន់តែខ្លាំង និងពិបាកគ្រប់គ្រងអំឡុងពេលអាកាសធាតុក្តៅ និងរាំងស្ងួត។ |
| តើវាអាចធ្វើឱ្យអន្តរាយអ្វីខ្លះដល់មនុស្ស ឬបរិស្ថាន? | វាមានសារៈសំខាន់ណាស់ក្នុងការគិតអំពីផលប៉ះពាល់ទៅនឹងប្រព័ន្ធអេកូដែលងាយរងគ្រោះ ដូចជា តំបន់ដីសើម និងផ្លូវទឹក ក៏ដូចជាតំបន់ជុំវិញទីលំនៅដ្ឋាន មន្ទីរពេទ្យ សាលារៀន និងផ្លូវថ្នល់។ |

## ៣. គណនាពីចំណាត់ថ្នាក់ហានិភ័យ

បន្ទាប់ពីអ្នកបានគិតអំពីផលវិបាក និងភាពទំនងជាកើតមានឡើងនៃហានិភ័យ អ្នកចាំបាច់ត្រូវមើលវារួមគ្នាដើម្បីធ្វើការគណនាចំណាត់ថ្នាក់ហានិភ័យរួម។

រូបភាពទី២ បង្ហាញពីឧទាហរណ៍នៃម៉ាទ្រីសហានិភ័យដែលអ្នកអាចប្រើ។ នៅក្នុងម៉ាទ្រីសហានិភ័យ ភាពទំនងជាកើតមានឡើង និងផលវិបាកត្រូវបានផ្តល់ពិន្ទុ
ដែលអ្នកអាចផ្គូរផ្គងលើម៉ាទ្រីស ដើម្បីដាក់ចំណាត់ថ្នាក់ហានិភ័យពីទាប ទៅខ្លាំង។
មានឧបករណ៍ផ្សេងទៀតដែលអ្នកអាចប្រើដើម្បីគណនាហានិភ័យដែល មានចុះបញ្ជីនៅក្នុង *SA/SNZ HB 89:2013 ការគ្រប់គ្រងហានិភ័យ - គោលការណ៍ណែនាំស្តីពីបច្ចេកទេសនៃការវាយតម្លៃហានិភ័យដែលអាចទទួលបាន ពីស្តង់ដារអូស្ត្រាលី។*

ហេតុផលដើម្បីផ្តល់នូវចំណាត់ថ្នាក់ហានិភ័យ គឺដើម្បីជួយអ្នកក្នុងការធ្វើការសម្រេចចិត្តអំពីរបៀបគ្រប់គ្រងហានិភ័យ។

***រូបភាពទី២ៈ គំរូម៉ាទ្រីសហានិភ័យ***

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ភាពអន្តរាយធ្ងន់ធ្ងរអចិន្ត្រៃយ៍ ឬយូរអង្វែង ដល់បរិស្ថាន ឬគំរាមកំហែងដល់ជីវិត ឬភាពអន្តរាយយូរអង្វែងដល់សុខភាព និងសុខុមាលភាព របស់មនុស្ស។ | ផលវិបាក | ធ្ងន់ធ្ងរ | មធ្យម | ខ្ពស់ | ខ្ពស់ | ខ្លាំង | ខ្លាំង |
| ភាពអន្តរាយធ្ងន់ធ្ងរដល់បរិស្ថាន ឬភាពអន្តរាយកម្រិតខ្ពស់ដល់សុខភាព និងសុខុមាលភាពរបស់មនុស្ស។ | | សំខាន់ | មធ្យម | មធ្យម | ខ្ពស់ | ខ្ពស់ | ខ្លាំង |
| ភាពអន្តរាយកម្រិតមធ្យមដល់ដល់សុខភាព និងសុខុមាលភាពរបស់មនុស្ស ឬបរិស្ថាន ក្នុងរយៈពេលយូរ។ | | ដែលមិនខ្លាំងពេក | ទាប | មធ្យម | មធ្យម | ខ្ពស់ | ខ្ពស់ |
| ឥទ្ធិពលតិចតួចទៅលើបរិស្ថាន ឬឱកាស តិចនៃឥទ្ធិពលលើសុខភាព និងសុខុមាលភាពរបស់មនុស្ស។ | | តិចតួច | ទាប | ទាប | មធ្យម | មធ្យម | ខ្ពស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មិនមាន<br>ឬមានឥទ្ធិពលតិចតួចទៅលើ បរិស្ថាន<br>ឬមិនមានឥទ្ធិពលដល់សុខភាព<br>និងសុខុមាលភាពរបស់មនុស្ស។ | | ទាប | ទាប | ទាប | ទាប | មធ្យម | មធ្យម |
| | | | កម្រណាស់ | មិនទំនងជា | អាចកើតមាន | ទំនងជា | ប្រាកដច្បាស់ |
| | | | **ភាពទំនងជាកើតមានឡើង** | | | | |
| | | | អាចកើតឡើងប៉ុន្តែប្រហែលជាមិនដែលនឹងកើតឡើង | មិនទំនងជាកើតឡើងនៅក្នុងកាលៈទេសៈធម្មតាទេ | អាចកើតឡើងនៅពេលខ្លះ | រំពឹងថានឹងកើតឡើងនៅពេលណាមួយ | រំពឹងថានឹងកើតឡើងជាទៀងទាត់ក្នុងកាលៈទេសៈធម្មតា |

***ការពិពណ៌នាអំពីចំណាត់ថ្នាក់ហានិភ័យ***

| **កម្រិតហានិភ័យ** | **ការពិពណ៌នា** |
|---|---|
| ខ្លាំង | កម្រិតហានិភ័យដែលមិនអាចទទួលយកបានទាំងស្រុង។ ឈប់ធ្វើការ ហើយចាត់វិធានការភ្លាមៗ។ |
| ខ្ពស់ | កម្រិតហានិភ័យដែលមិនអាចទទួលយកបាន។ ដាក់ការត្រួតពិនិត្យនៅនឹងកន្លែង ដើម្បីកាត់បន្ថយហានិភ័យ។ |
| មធ្យម | អាចទទួលយកបាន ប្រសិនបើការត្រួតពិនិត្យត្រូវបានដាក់នៅនឹងកន្លែងមាន។ ព្យាយាមកាត់បន្ថយគ្រោះថ្នាក់ឱ្យដល់កម្រិតទាប។ |
| ទាប | កម្រិតហានិភ័យដែលអាចទទួលយកបាន។ ព្យាយាមកម្ចាត់ ហានិភ័យ ប៉ុន្តែកម្រិតហានិភ័យខ្ពស់ គឺសំខាន់ជាង។ |

*ទំព័រនេះត្រូវបានទុកឱ្យនៅទទេដោយចេតនា។*

## ជំហានទី 3: អនុវត្តការគ្រប់គ្រង




ដាក់ចំណាត់ថ្នាក់ជម្រើសរបស់អ្នកសម្រាប់ការត្រួតពិនិត្យហានិភ័យទៅតាមលំដាប់លំដោយ ចាប់ពីមានប្រសិទ្ធភាពបំផុត ទៅមានប្រសិទ្ធភាពតិចបំផុត ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៣។ នៅក្នុងចំណាត់ថ្នាក់នេះ អ្នកដាក់ការគ្រប់គ្រង ក្នុងចំណោមប្រភេទមួយ ក្នុងចំណោមប្រភេទទាំងបីខាងក្រោម។

**ការលុបបំបាត់ចោល៖** ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពបំផុត គឺកម្ចាត់ចោលគ្រោះថ្នាក់ និងហានិភ័យណាមួយជាមួយគ្នា។

***ការដាក់ជំនួសហានិភ័យ ឬការគ្រប់គ្រងបែបវិស្វកម្ម៖*** ការគ្រប់គ្រប់ដែលមានប្រសិទ្ធភាពទីពីរ ជំនួសឱ្យមូលហេតុនៃគ្រោះថ្នាក់ជាមួយអ្វីមួយដែលមានសុវត្ថិភាព ជាង ឬការគ្រប់គ្រងហានិភ័យជាមួយការគ្រប់គ្រងបែបវិស្វកម្ម។ ដើម្បីឱ្យមានដំណើរការ ការគ្រប់គ្រងទាំងនេះចាំបាច់ត្រូវមានសកម្មភាពឯករាជ្យរបស់មនុស្ស។

- ***ការដាក់ជំនួស*** មូលហេតុនៃគ្រោះថ្នាក់ជាមួយជម្រើសដែលមានសុវត្ថិភាពជាង គឺមានប្រសិទ្ធភាពជាងការដាក់ការគ្រប់គ្រងនៅនឹងកន្លែង។
- ***ការគ្រប់គ្រងបែបវិស្វកម្ម*** គឺជាការគ្រប់គ្រងគ្រោះថ្នាក់ជាក់ស្តែង។ ឧទាហរណ៍ រួមមានជញ្ជាំងទប់ការពារការលេចធ្លាយ និងប្រព័ន្ធបិទដោយ ស្វ័យប្រវត្តិសម្រាប់គ្រឿងម៉ាស៊ីន។

***ការគ្រប់គ្រងផ្នែករដ្ឋបាល និងការប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE)៖*** ការគ្រប់គ្រងដែលមានប្រសិទ្ធិភាពតិចបំផុត ពឹងផ្អែកទៅលើមនុស្សដែល បំពេញមុខការត្រឹមត្រូវ ឬមានការប្រុងប្រយ័ត្នគ្រប់ពេលវេលា។

- រួមមានការបណ្តុះបណ្តាល វិធីនីតិ គោលនយោបាយ ការត្រួតពិនិត្យ ឬរៀបចំផែនការវេនការងារ ដែលកាត់បន្ថយការគំរាមកំហែងនៃគ្រោះថ្នាក់ ឬយ៉ាងហោចណាស់អនុញ្ញាតឱ្យមនុស្សដឹងអំពីគ្រោះថ្នាក់។ ឧទាហរណ៍ រួមមានដំណើរការណែនាំពីការងារ ប្រព័ន្ធអនុញ្ញាតឱ្យចូលកន្លែងការងារ និងការបណ្តុះបណ្តាល។
- **PPE** គួរតែបានយកប្រើប្រាស់ ប្រសិនបើមនុស្សអាចប៉ះពាល់នឹងការពុល ឬកាកសំណល់ដែលនាំឱ្យអន្តរាយ។

រួមគ្នា ធាតុផ្សំទាំងនេះបង្កើតជាលំដាប់នៃស្តង់ដារគ្រប់គ្រងហានិភ័យ។

***រូបភាពទី៣៖ លំដាប់គ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យ***




ជួនកាលវាពិបាកក្នុងការគណនាពីភាពទំនងជាកើតមានឡើង ឬផលវិបាកនៃគ្រោះថ្នាក់។ ប្រសិនបើមានការគ្រប់គ្រងដែលអ្នកអាចដាក់នៅនឹងកន្លែងបាន យ៉ាងងាយស្រួលនោះ អ្នកគួរតែប្រើវាយ៉ាងហោចណាស់ - ដែលគេហៅថា គោលការណ៍ប្រុងប្រយ័ត្នទុកជាមុន។

## ការគ្រប់គ្រងដើម្បីទប់ស្កាត់ និងបន្ធូរបន្ថយ

អ្នកអាចបែងចែកគ្រប់គ្រងជាពីរប្រភេទ គឺការទប់ស្កាត់ និងការបន្ធូរបន្ថយ។

- ***ការគ្រប់គ្រងដើម្បីទប់ស្កាត់*** បញ្ឈប់កុំឱ្យគ្រោះថ្នាក់កើតមានឡើងពីដើមដំបូង។
- ***ការគ្រប់គ្រងដើម្បីបន្ធូរបន្ថយ*** កាត់បន្ថយនូវផលវិបាក ឬការខូចខាតបណ្តាលមកព្រឹត្តិការណ៍ដែលនាំឱ្យអន្តរាយ។

ការគ្រប់គ្រងដើម្បីទប់ស្កាត់ កម្ចាត់ចោលនូវហានិភ័យទាំងស្រុង ខណ:ដែលការគ្រប់គ្រងដើម្បីបន្ធូរបន្ថយ ព្យាយាមដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដែលនាំឱ្យ អន្តរាយនូវហានិភ័យណាមួយដែលអ្នកមិនអាចកម្ចាត់ចោលបាន។

***តារាងទី៥៖ ឧទាហរណ៍ខ្លះៗនៃការគ្រប់គ្រងដើម្បីទប់ស្កាត់ និងបន្ធូរបន្ថយ***

| ***ការគ្រប់គ្រងដើម្បីទប់ស្កាត់*** | ***ការគ្រប់គ្រងដើម្បីបន្ធូរបន្ថយ*** |
|---|---|
| ការរក្សាទុកវត្ថុរាវ និងឧស្ម័នប្រកបដោយគ្រោះថ្នាក់ រួមមានកាកសំណល់ | ឧបករណ៍ជូតសម្អាតការកំពប់ ដែលអាចយកប្រើបានយ៉ាងឆាប់រហ័ស ប្រសិនបើមានការកំពប់ |
| ប្រព័ន្ធអនុញ្ញាតឱ្យចូលកន្លែងការងារ | ឧបករណ៍ពន្លត់អគ្គីភ័យ |
| ប្រព័ន្ធសុវត្ថិភាព | ផែនការគ្រប់គ្រងគ្រាមានអាសន្ន |
| ការធ្វើតេស្ត និងការថែទាំឧបករណ៍ជាទៀងទាត់ | ជញ្ជាំងទប់ការពារការលេចធ្លាយ |
| កម្មវិធីរាវរកការលេចធ្លាយ និងការជួសជុល | ការឆាបឆេះឧស្ម័ន ដែលគេស្គាល់ដែរថាគំនរឆាបឆេះ |

## បញ្ជីគ្រោះថ្នាក់ និងហានិភ័យ

អ្នកអាចកត់ត្រាចុះនូវគ្រោះថ្នាក់ទាំងអស់ដែលបានកំណត់ និងហានិភ័យរបស់វានៅក្នុងបញ្ជីមួយ។ នេះមានន័យថា បុគ្គលិកសំខាន់ៗអាចយល់ដឹងពីហានិភ័យ របស់អាជីវកម្ម ហើយគិតអំពីហានិភ័យដែលជាផ្នែកនៃដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

បញ្ជីនេះអាចរួមបញ្ចូលការគ្រប់គ្រងដែលមានរួចស្រេចសម្រាប់គ្រោះថ្នាក់ និងហានិភ័យនីមួយៗ។ អ្នកក៏អាចប្រើប្រាស់វាបានដែរ ដើម្បីជួយកំណត់សម្រាប់ ពេលណាការគ្រប់គ្រងថ្មីអាចដាក់បន្ថែម ដើម្បីកាត់បន្ថយហានិភ័យណាមួយដែលកំពុងតែកើតមាន។

ប្រសិនបើអ្នកពិនិត្យមើលបញ្ជីឱ្យបានទៀងទាត់ អាជីវកម្មរបស់អ្នកនឹងអាចផ្តោតទៅលើការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការកែលម្អ
ការគ្រប់គ្រងគ្រោះថ្នាក់របស់អ្នកជាបន្តបន្ទាប់ដែរ។

យើងបានដាក់បញ្ចូលនូវឧទាហរណ៍មួយនៃបញ្ជីគ្រោះថ្នាក់ និងហានិភ័យនៅចុងសៀវភៅណែនាំនេះ។

# ការគ្រប់គ្រងហានិភ័យ

ជំហានទីបួន៖ ឆែកមើលការគ្រប់គ្រង



## ជំហានទី 4: ផែកមើលការគ្រប់គ្រង

ការគ្រប់គ្រងដែលអ្នកបានដាក់នៅនឹងកន្លែងដើម្បីទប់ស្កាត់ ឬកាត់បន្ថយហានិភ័យ ចាំបាច់ត្រូវតែបានត្រួតពិនិត្យ ដើម្បីប្រាកដថាវានៅដំណើរការ ដូចដែលវាត្រូវបានសន្មត់ឱ្យដំណើរការ។

### *ការផែកមើលការគ្រប់គ្រង*

ការផែកមើលការគ្រប់គ្រងប្រើវិធីសាស្រ្តដូចគ្នាដែលអ្នកបានប្រើនោះដែរ ដើម្បីកំណត់ពីគ្រោះថ្នាក់នៅក្នុងជំហានទី១។

វិធីសាស្រ្តទូទៅដែលអ្នកអាចប្រើដើម្បីផែកមើលពីប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់អ្នក រួមមាន៖

- ការត្រួតពិនិត្យ និងការជម្រះបញ្ជីជាទៀងទាត់នៅតាមទីតាំង
- ការនិយាយជាមួយបុគ្គលិក អ្នកម៉ៅ អ្នកជួលទីលំនៅ និងម្ចាស់ផ្ទះ
- ការពិនិត្យ ការសាកល្បង និងការថែរក្សាប្រព័ន្ធគ្រប់គ្រងហានិភ័យ
- ការប្រើប្រាស់ព័ត៌មាន ដូចជាការណែនាំរបស់ក្រុមហ៊ុនផលិត និងអ្នកផ្គត់ផ្គង់
- ការវិភាគឯកសារ និងទិន្នន័យ ដូចជារបាយការណ៍ឧប្បត្តិហេតុ និងគ្រោះថ្នាក់ដែលហៀបនឹងកើតមាន។

ប្រសិនបើអ្នកធ្វើការផែកមើលទាំងនេះ**ឱ្យ**បានទៀងទាត់ នោះអ្នកអាចកំណត់ពីការគ្រប់គ្រងដែលមិនដំណើរការ ក៏ដូចជាឱកាសដើម្បីធ្វើឱ្យប្រសើរឡើងដែរ។

### *ការរក្សាការគ្រប់គ្រងដោយប្រសិទ្ធភាព*

ដើម្បីរក្សាការគ្រប់គ្រង និងធ្វើឱ្យប្រាកដថាវានៅតែមានប្រសិទ្ធិភាព អ្នកចាំបាច់ត្រូវ៖

- ពិនិត្យឡើងវិញនូវគ្រោះថ្នាក់ និងការវាយតម្លៃហានិភ័យឱ្យបានទៀងទាត់ ដោយព្រោះថាវាអាចផ្លាស់ប្តូរក្នុងរយៈពេល
- ពិនិត្យឡើងវិញ ធ្វើតេស្ត និងរក្សាការគ្រប់គ្រងបែបវិស្វកម្មទាំងអស់ឱ្យបានទៀងទាត់
- ធ្វើឱ្យនរណាម្នាក់ទទួលខុសត្រូវចំពោះហានិភ័យ និងការគ្រប់គ្រងរបស់ពួកគេ
- និយាយជាមួយបុគ្គលិក និងអ្នកដទៃឱ្យបានទៀងទាត់ ដូចជាស្ថានប័នធានារ៉ាប់រង និងអ្នកតំណាងសេវាកម្មសង្គ្រោះបន្ទាន់
- ប្រាស្រ័យទាក់ទងទំនាក់**ឱ្យបាន**ច្បាស់លាស់អំពីការគ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យដល់នរណាម្នាក់ដែលគ្រោះថ្នាក់ទាំងនេះអាចប៉ះពាល់
- បណ្តុះបណ្តាលបុគ្គលិកឱ្យបានទៀងទាត់ រួមទាំងការបណ្តុះបណ្តាលរំលឹកឡើងវិញសម្រាប់ការគ្រប់គ្រងផ្នែករដ្ឋបាល។

## ឯកសារភ្ជាប់: ឧទាហរណ៍អំពីបញ្ជីគ្រោះថ្នាក់ និងហានិភ័យ

កំណត់ចំណាំ៖ បញ្ជីគ្រោះថ្នាក់នេះគឺសមស្របសម្រាប់អាជីវកម្មដែលមានហានិភ័យទាប។ អាជីវកម្មដែលមានហានិភ័យខ្ពស់ ឬអាជីវកម្មធំៗ ប្រហែលជាចាំបាច់ត្រូវការបញ្ជីស្មុគស្មាញជាងនេះ។

| **ការពិនិត្យឡើងវិញ៖** | | **កាលបរិច្ឆេទ៖** | | **អ្នកចូលរួម៖** | |
|---|---|---|---|---|---|

| លេខ | គ្រោះថ្នាក់ | គ្រោះថ្នាក់ដែលមានសក្តានុពល | ការវាយតម្លៃហានិភ័យ | | | ការគ្រប់គ្រងដែលមានស្រាប់ | តើតម្រូវឱ្យមានការគ្រប់គ្រងបន្ថែមអ្វីខ្លះ? | សកម្មភាព | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ផលវិបាក | ភាពទំនងជាកើតមានឡើង | ចំណាត់ថ្នាក់ហានិភ័យ | | | សកម្មភាពដំណើរការដោយ | កាលបរិច្ឆេទកំណត់ | កាលបរិច្ឆេទបញ្ចប់ |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ការបោះពុម្ពផ្សាយ 1695.1*   ខែសីហា ឆ្នាំ២០១៨
*នេះជំនួស 1695   បោះពុម្ពផ្សាយនៅខែឧសភា ឆ្នាំ២០១៨

អនុញ្ញាត និងបោះពុម្ពផ្សាយដោយ EPA Victoria
Level 3, 200 Victoria Street, Carlton VIC 3053
1300 372 842 (1300 EPA VIC)

ការបោះពុម្ពផ្សាយនេះ អាចរកឃើញនៅតាមអនឡាញជាសណ្ឋាន PDF នៅតាមវិបសៃ **epa.vic.gov.au**

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែភាសា ឬចង់បកប្រែឯកសារនេះ
សូមហៅទូរស័ព្ទលេខ
131 450 ហើយប្រាប់ពីភាសាដែលអ្នកនិយមពេញចិត្ត។